**ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**សេចក្តីប្រកាសព័ត៌មាន**

លេខ: 06 PR-17/EoJ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧

# ការចាប់ផ្តើមទទួលពាក្យសុំអាហារូបករណ៍ជប៉ុន សម្រាប់ឆ្នាំ២០១៨

ស្ថានទូតជប៉ុនមានសេចក្តីសោមនស្សរីករាយសូមជម្រាបជូនថា ស្ថានទូតបានចាប់ផ្តើមបើកទទួលពាក្យសុំអាហារូបករណ៍ជប៉ុនសម្រាប់ឆ្នាំ២០១៨ ជូនទៅដល់សិស្ស និស្សិតកម្ពុជា។ MEXT Scholarship គឺជាអាហារូបករណ៍ធំជាងគេក្នុងចំណោមអាហារូបករណ៍ដ៏ទៃផ្សេងទៀត សម្រាប់ការទៅសិក្សានៅប្រទេសជប៉ុនដែលផ្តល់ដោយ ក្រសួងអប់រំជប៉ុន ដែលហៅកាត់ថា MEXT។

ព័ត៌មានលម្អិតទាក់ទងទៅនិងអាហារូបករណ៍មានដូចខាងក្រោមៈ

**១. ប្រភេទនៃអាហារូបករណ៍**

- ថ្នាក់ក្រោយឧត្តមសិក្សា
- ថ្នាក់ឧត្តមសិក្សា
- ថ្នាក់មធ្យមសិក្សាបច្ចេកទេស
- ថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈ

**២. ការដាក់ពាក្យប្រឡង**

- ពាក្យសុំប្រឡងអាចរកបាននៅនាយកដ្ឋានអាហារូបករណ៍នៃក្រសួងអប់រំ យុវជន និងកីឡា ដែលមានអាសយដ្ឋានៈ

#២៣,ផ្លូវលេខ៣៦០, សង្កាត់បឹងកេងកង១, ខណ្ឌចំការមន (ខាងកើតស្ថានីយទូរទស្សន៍អប្សរា ចម្ងាយប្រមាណ៥០ម៉ែត្រ)

- សូមបេក្ខជនទាំងអស់ធ្វើការដាក់ពាក្យ មកកាន់នាយកដ្ឋានអាហារូបករណ៍ អោយបានត្រឹមថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧។

## ៣. កាលបរិច្ឆេទប្រឡង

ការប្រឡងសរសេរនឹងប្រព្រឹត្តិឡើងនៅវិទ្យាល័យព្រះស៊ីសុវត្ថិ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៧។ បេក្ខជនដែលជាប់ក្នុងការប្រឡងសរសេរ នឹងត្រូវឆ្លងកាត់ការសម្ភាសនៅស្ថានទូតជប៉ុន។ ចំពោះលទ្ធផលចុងក្រោយនឹងត្រូវប្រកាសនាអំឡុងចុងខែធ្នូ។

ស្ថានទូតជប៉ុន រួមសហការជាមួយសមាគមអតីតនិស្សិតខ្មែរពីប្រទេសជប៉ុន នឹងធ្វើបទបង្ហាញស្តីអំពីអាហារូបករណ៍ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជាជប៉ុន(CJCC) នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ សម្រាប់សិស្សនិស្សិតដែលមានបំណងចង់ទៅបន្តការសិក្សានៅប្រទេសជប៉ុន។

ចាប់តាំងពីឆ្នាំ១៩៩២មក និស្សិតកម្ពុជាចំនួនជាង១០០០នាក់បានបន្តការសិក្សានៅប្រទេសជប៉ុនតាមរយៈអាហារូបករណ៍MEXT។ ពួកគេក៏បានរួមចំនែកក្នុងការអភិវឌ្ឍប្រទេសកម្ពុជា និងយល់ដឹងពីប្រជាជនជប៉ុន ក៏ដូចជាពង្រឹងនូវចំណងមិត្តភាពរវា ប្រទេសកម្ពុជានិងប្រទេសជប៉ុនផងដែរ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន តាមរយៈទូរស័ព្ទលេខ ០២៣ ២១៨ ៨៧០ (១១២៣) ឬ ផ្ញើអ៊ីម៉េលមកកាន់អាស័យដ្ឋានៈ info.jpn@pp.mofa.go.jp ។